**សកម្មភាព** ៖ ល្បែងបង្កើតព្យាណូ

**ចិត្តចលភាព** ៖ បំណិនចលនាតូច៖

ការហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែក

**សិក្សាសង្គម** ៖ ចម្រៀងនិងតន្ត្រី៖ ចំណេះដឹងបច្ចេកទេស ចលនា ការច្នៃប្រឌិតនិងបទពិសោធន៍ផ្នែកតន្ត្រី

៖ គំនូរនិងសកម្មភាពកសាង៖ ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈ ការបង្កើតរូបភាព។

**ភាសាខ្មែរ** ៖ ការស្គាល់តួអក្សរ៖ ការយល់ដឹងអំពីភាពខុសគ្នានៃសូរសំឡេង។

**គោលបំណង**

**ចិត្តចលភាព** ៖ បំណិនសម្បទា៖

ប្រាប់បានពីរបៀបធ្វើចលនាដៃដោយការទប់លំនឹង

និងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងអ្វីមួយ។

**សិក្សាសង្គម** ៖ វិជ្ជាសម្បទា៖ ប្រាប់បានពីការទះដៃបន្ទរ ឬគោះសម្ភារនានា តាមចង្វាក់ភ្លេង។

បំណិនសម្បទា៖ ទះដៃបន្ទរ គោះសម្ភារនានាតាមចង្វាក់ភ្លេង។

**ភាសាខ្មែរ** ៖ វិជ្ជាសម្បទា៖ ប្រាប់បានពីសូរសំឡេងសត្វឬវត្ថុនានានៅក្នុងបរិស្ថាន។

បំណិនសម្បទា៖ បង្ហាញពីភាពខុសគ្នានៃសូរសំឡេង ។

**កម្រិតសិក្សា** ៖ ទាប មធ្យមនិងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ របៀបទី១៖ បន្ទះក្តារ កាំភ្លើងបាញ់កាវ តង្កៀបគាបសក់

ឈើចង្កឹះ ដង្កាប់ មេដែកកឹបនិងគម្របធុងនំ បើមាន។

របៀបទី២៖ មាន បន្ទះក្តារ តង្កៀបគាបសក់ កៅស៊ូ ចង្កឹះ

ដបទឹកសុទ្ធជាដើម...

**ការរៀបចំ** ៖ បង្កើតជាព្យាណូមួយសម្រាប់បង្ហាញទៅកាន់កុមារ មុននឹងឱ្យកុមារចាប់ផ្តើមលេង ឬបង្កើត។

**សេចក្តីណែនាំ** ៖

1. ដំបូងសួរកុមារពីឧបករណ៍តន្ត្រីជាមុនសិន ថាតើកុមារស្គាល់វាបានប៉ុន្មាន? តើកូនៗស្គាល់ព្យាណូដែរឬទេ?

2. ប្រាប់កុមារទាំងអស់ថា ថ្ងៃនេះពួកយើងនឹងបង្កើតឧបករណ៍តន្ត្រីមួយដែលមានឈ្មោះថា ព្យាណូ។
3. តើកូនៗចង់ចេះបង្កើតព្យាណូដែរឬទេ?
4. គ្រូបង្ហាញព្យាណូដែលគ្រូបានបង្កើតនិងបានត្រៀមសម្រាប់បង្ហាញនិងប្រាប់ពីរបៀបធ្វើវាទៅកាន់កុមារជាមុនសិនដែរ ។
5. ព្យាណូមាន២ប្រភេទ

   **នេះជាប្រភេទទី១៖**

   ★ បាញ់កាវនៅចំពាក់កណ្តាលបន្ទះក្តារនិងបិទឈើចង្កឹះ ប្រវែងគ្នានឹងបន្ទះក្តារដែរ
   ★ កាត់តង្កៀបគាបសក់កន្លែងដែលបត់ចេញនិងពត់វារៀងកោងបន្តិច
   ★ បាញ់គ្រាប់កឹបមួយគ្រាប់កៀនចង្កឹះ
   ★ ស៊កតង្កៀបគាបសក់ចូលក្នុងគ្រាប់កឹបនោះដោយគង ជាមួយនឹងឈើចង្កឹះតាមប្រវែងនីមួយៗ
   ★ បាញ់គ្រាប់កឹបបន្ថែមទៀតដើម្បីឱ្យមានភាពរឹងមាំ
   ★ តម្រៀបតង្កៀបនិងបាញ់គ្រាប់កឹបបន្តបន្ទាប់គ្នាពីវែងមកខ្លី
   ★ កឹបរហូតបែបនេះជាការស្រេច។

   **នេះជាប្រភេទទី2៖**

   ★ បន្ទះក្តារមួយ ដាក់គាបពីលើនិងក្រោមដោយឈើចង្កឹះបែបនេះ
   ★ បន្ទាប់ចងវាឱ្យរឹងមាំល្អជាមួយកៅស៊ូ កាន់តែណែនកាន់តែល្អ
   ★ បន្ទាប់មក ស៊កតង្កៀបគាបសក់ម្តងមួយៗ តាមប្រវែងពីខ្លីទៅវែងដូចក្នុងវីដេអូនេះ
   ★ បន្ទាប់ពីដាក់វាបានគ្រប់គ្រាន់រហើយ យើងត្រូវដាក់ឈើចង្កឹះមួយដើមទៀតសង្កត់នៅខាងគល់បែបនេះ
   ★ ចងរុំជាមួយកៅស៊ូឱ្យច្រើន ឱ្យវាមានភាពរឹងមាំ កុំឱ្យរបូតចេញក្រៅជាការស្រេច។
6. នាំកុមារលេងសាកល្បងជាមួយព្យាណូដែលពួកគេបានធ្វើរួចម្នាក់ម្តងៗជាការស្រេច។